ក្រសួងពាណិជ្ជកម្ម

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# សេចក្ដីប្រកាសព័ត៌មាន

ក្រសួងពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា មានកិត្តិយសសូមជម្រាបជូន ក្រុមហ៊ុន ពាណិជ្ជករ សមាគមដឹកជញ្ជូនទំនិញនាំចេញ-នាំចូល និងសាធារណជន ឱ្យបានជ្រាបថា នាពេលបច្ចុប្បន្ន ដោយប្រឈមនឹងស្ថានភាពដ៏ស្រួចស្រាវនៃការរីករាលដាលជំងឺឆ្លងកូវីដ-១៩ ជាពិសេសមេរោគបំប្លែងខ្លួនថ្មី "អូមីក្រុង" ដែលមានហានិភ័យខ្ពស់ បណ្ដាប្រទេសក្នុងតំបន់និងសកលលោកបានចាប់ផ្ដើមដាក់ចេញនូវវិធានការរឹតបន្តឹងផ្នែកសុខាភិបាលនិងរឹតត្បិតការធ្វើដំណើរចេញ-ចូលនិងឆ្លងកាត់ សំដៅបង្ការនិងទប់ស្កាត់ការរីករាលដាលជាយថាហេតុ។

យោងតាមសេចក្ដីជូនដំណឹងនៃក្រសួងឧស្សាហកម្មនិងពាណិជ្ជកម្មនៃសាធារណរដ្ឋសង្គមនិយមវៀតណាម បានឱ្យដឹងថា សកម្មភាពនាំចូល និងនាំចេញទំនិញនៅច្រកព្រំដែនវៀតណាមនិងចិនបានជួបប្រទះការកកស្ទះយ៉ាងខ្លាំង ជាពិសេសនៅច្រកទ្វារព្រំដែនខេត្ត Lang Son និងខេត្ត Quang Ninh ដែលបណ្ដាលជាចម្បងមកពីការរឹតបន្តឹងវិធានការបង្ការការរីករាលដាលជំងឺកូវីដ-19 របស់ប្រទេសចិនក្រោមគោលនយោបាយ "Zero Covid"។ ក្រសួងឧស្សាហកម្មនិងពាណិជ្ជកម្មបានបញ្ជាក់ថា គិតត្រឹមថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២១ ក្នុងខេត្តទាំងពីរខាងលើ មានរថយន្តប្រមាណជាង ៦០០០គ្រឿង កំពុងរង់ចាំការនាំចេញទៅកាន់ប្រទេសចិន។ តាមការវាយតម្លៃជារួមឃើញថា បរិមាណទំនិញដែលអាចនាំចេញបាននៅតាមច្រកព្រំដែនសំខាន់ៗមួយចំនួនជាមួយប្រទេសចិនមានចំនួនត្រឹមតែ ២៥-៣០% ប៉ុណ្ណោះ បើប្រៀបធៀបទៅនឹងលក្ខខណ្ឌនាំចេញធម្មតា។ លើសពីនេះ ច្រកទ្វារព្រំដែនមួយចំនួនទៀតនៅតែបន្តផ្អាកដំណើរការគយជាបណ្ដោះអាសន្ន រហូតដល់មានសេចក្ដីជូនដំណឹងជាថ្មី។

ស្ថិតក្នុងបរិការណ៍នេះ ក្រសួងពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា សូមជូនដំណឹងដល់ក្រុមហ៊ុន ពាណិជ្ជករ និងសមាគមដឹកជញ្ជូនទំនិញនាំចេញ-នាំចូល ឱ្យបានជ្រាប និងពិនិត្យលទ្ធភាពរកមធ្យោបាយនិងវិធីនាំចេញផ្សេង ដើម្បីជៀសវាងហានិភ័យនិងបញ្ហានានាដែលបណ្ដាលមកពីការកកស្ទះតាមរយៈការបញ្ជូនទំនិញឆ្លងកាត់ប្រទេសវៀតណាមទៅកាន់ប្រទេសចិន តាមច្រកព្រំដែនគោក រវាងប្រទេសវៀតណាម និងប្រទេសចិន។

ក្រសួងពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា រួមជាមួយនិងក្រសួង-ស្ថាប័នពាក់ព័ន្ធកំពុងពិនិត្យនិងបន្តតាមដានយ៉ាងយកចិត្តទុកដាក់នូវការវិវត្តនៃសភាពការណ៍នេះ ហើយនឹងជម្រាបជូនអំពីវឌ្ឍនភាពជាបន្តបន្ទាប់ទៀត។

សូម ក្រុមហ៊ុន ពាណិជ្ជករ សមាគមដឹកជញ្ជូនទំនិញនាំចេញ-នាំចូល និងសាធារណជន មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃចន្ទ ១កើត ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី៣ ខែមករា ឆ្នាំ២០២២